ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រជាតិ
# ស្តីពី
# ការផ្គត់ផ្គង់ទឹកស្អាត
# និងការលើកកម្ពស់អនាម័យនៅជនបទ
# ឆ្នាំ ២០១៤-២០២៥




បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃសុក្រ ១០កើត ខែបុស្ស ឆ្នាំម្សាញ់ ព.ស. ២៥៥៧ ត្រូវនឹងថ្ងៃទី ១០ ខែមករា គ.ស. ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា គាំទ្រផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ ២០១៤ -២០២៥

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមគាំទ្រផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទឆ្នាំ ២០១៤ - ២០២៥ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០០០ និងក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០០៣ ។ ផែនការយុទ្ធសាស្ត្រជាតិនេះមានគោលបំណងធ្វើឱ្យសេវាទឹកស្អាត និងអនាម័យនៅជនបទមានភាពប្រសើរឡើង និងប្រកបដោយនិរន្តរភាពដើម្បីរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ ។

ដើម្បីសម្រេចបាននូវគោលបំណងនេះ រាជរដ្ឋាភិបាលបានអនុម័តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដែលបានកំណត់ថា នៅឆ្នាំ ២០១៥ ប្រជាជននៅជនបទ ៥០% នឹងទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អ និងប្រជាជននៅជនបទ ៣០% នឹងទទួលបានការលើកកម្ពស់អនាម័យ ។ គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ បានកំណត់នូវទស្សនវិស័យ “នៅឆ្នាំ ២០២៥ ប្រជាជនគ្រប់រូបនៅសហគមន៍ជនបទ

ត្រូវមានការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព" ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះក្រុមការងារទាំងអស់ រួមមានក្រសួងអភិវឌ្ឍន៍ជនបទ អន្តរក្រសួង ជាពិសេសទីស្ដីការគណៈរដ្ឋមន្ត្រី និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានខិតខំប្រឹងប្រែងរៀបចំផែនការយុទ្ធសាស្ត្រជាតិនេះឡើង ។

ខ្ញុំសូមអំពាវនាវដល់សហគមន៍ទាំងមូលត្រូវចូលរួមគាំទ្រឱ្យបានខ្លាំងក្លា ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះទទួលបានជោគជ័យ ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងជួររាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នឹងយកផែនការយុទ្ធសាស្ត្រជាតិនេះទៅប្រើប្រាស់ជាត្រីវិស័យសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

# សេចក្តីថ្លែងអំណរគុណ
# របស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ខ្ញុំមានកិត្តិយសដ៏ថ្លៃថ្លា ក្នុងនាមក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានរៀបចំឯកសារផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ ២០១៤-២០២៥ ។ ក្រសួងអភិវឌ្ឍន៍ជនបទមានភ័ព្វសំណាងជាពិសេសដោយបានទទួលការគាំទ្រយ៉ាងពេញទំហឹងពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ពីមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ ដែលប្រកបដោយសមត្ថភាព ឆន្ទៈ និងភាពស្វាហាប់ ជាពិសេសកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កា ជាមួយអន្តរក្រសួងស្ថាប័នក្រោមកិច្ចសម្របសម្រួលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានធ្វើឱ្យផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ ២០១៤-២០២៥ ទទួលបានការគាំទ្រ និងអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា ។

ដោយយល់យ៉ាងច្បាស់ពីផលប៉ះពាល់អវិជ្ជមាន នៃកង្វះការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យល្អនៅជនបទសម្រាប់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា និងបណ្តាដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិទាំងអស់ បានប្រមើលមើលនូវយុទ្ធសាស្ត្រគន្លឹះនានា វិភាគអំពីលទ្ធភាពនៃធនធានក្នុងការអនុវត្តនូវផែនការយុទ្ធសាស្ត្រនេះ តាមរយៈការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ សំដៅសម្រេចឱ្យបាននូវទស្សនវិស័យ “នៅឆ្នាំ ២០២៥ ប្រជាជនគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព” ។ ការខិតខំប្រឹងប្រែងទាំងនេះ គឺជាការចូលរួមចំណែកមួយយ៉ាងសំខាន់ ដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន និងកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ។

ក្រសួងអភិវឌ្ឍន៍ជនបទ ប្តេជ្ញាបំពេញការងារជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះឱ្យមានប្រសិទ្ធភាព និងសម្រេចបានជោគជ័យទៅតាមគោលដៅដែលបានកំណត់ ។ ខ្ញុំមានសុទិដ្ឋិនិយមចំពោះការគាំទ្រ និងកិច្ចសហប្រតិបត្តិការពីក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលអាជ្ញាធរមូលដ្ឋាន អង្គការជាតិ អង្គការអន្តរជាតិ ជាដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីធានាដល់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ឱ្យដំណើរការទៅដោយរលូន និងទទួលបានលទ្ធផលដូចការរំពឹងទុក។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជានិច្ចកាលតែងតែយកចិត្តទុកដាក់ដល់សុខភាព និងសេចក្តីសុខរបស់ប្រជាជន ហើយតែងតែគាំទ្រ និងផ្តល់អាទិភាពដល់វិស័យអភិវឌ្ឍន៍ជនបទជានិច្ច ។ ជាសក្ខីភាពពេលនេះ **សម្តេចតេជោ** បានផ្តល់អនុសាសន៍ណែនាំ និងគាំទ្រយ៉ាងខ្លាំងក្លាដល់ផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ២០១៤ - ២០២៥។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួង ស្ថាប័ន និងបណ្តាផ្នែកពាក់ព័ន្ធ ព្រមទាំងអង្គការជាតិ និងអន្តរជាតិ ជាដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានចូលរួមរៀបចំផែនការយុទ្ធសាស្ត្រជាតិនេះ និងប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការឱ្យកាន់តែរលូនថែមទៀត នៅក្រោមកិច្ចដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដើម្បីសម្រេចឱ្យបានជោគជ័យក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ ២០១៤-២០២៥។

ថ្ងៃសុក្រ ៩រោច ខែបុស្ស ឆ្នាំម្សាញ់ ព.ស. ២៥៥៧

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៤

**ជា សុផារ៉ា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រជាតិ

# ស្តីពី

# ការផ្គត់ផ្គង់ទឹកស្អាត

# និងការលើកកម្ពស់អនាម័យនៅជនបទ

# ឆ្នាំ២០១៤-២០២៥

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤

# មាតិកា


**១. សេចក្តីផ្តើម** ........ ១

**២. ចក្ខុវិស័យ** ........ ២

**៣. បេសកកម្ម** ........ ២

**៤. គោលបំណងនិងគោលដៅ** ........ ២

៤.១ គោលបំណង ........ ២

៤.២ គោលដៅ ........ ២

**៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ........ ២

៥.១ ការវិភាគជាយុទ្ធសាស្ត្រ ........ ២

៥.២ ទិសដៅជាយុទ្ធសាស្ត្រ ........ ៤

៥.៣ យុទ្ធសាស្ត្រ ........ ៤

**៦. សកម្មភាពការងារ** ........ ៥

៦.១ បង្កើតយន្តការសម្រាប់បង្កលក្ខណៈក្នុងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទប្រកបដោយនិរន្តរភាព ........ ៥

៦.២ បង្កើនហិរញ្ញប្បទានសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ ........ ៩

៦.៣ ជំរុញនិងលើកទឹកចិត្តប្រជាជននៅជនបទឱ្យទទួលបានការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយនិរន្តរភាព ........ ១០

៦.៤ ជំរុញនិងលើកទឹកចិត្តប្រជាជននៅជនបទ ឱ្យទទួលបានការលើកកម្ពស់អនាម័យប្រកបដោយនិរន្តរភាព ........ ១១

៦.៥ ជំរុញនិងលើកទឹកចិត្តប្រជាជន ឱ្យមានការផ្លាស់ប្តូរឥរិយាបថ ក្នុងការប្រើប្រាស់ទឹកស្អាតនិងអនាម័យប្រកបដោយនិរន្តរភាព ........ ១២

**៧. ធនធានហិរញ្ញវត្ថុ** ........ ១៣

**៨. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ** ........ ១៣

**៩. សេចក្តីសន្និដ្ឋាន** ........ ១៣

**សន្ទានុក្រម** ........ I&II

## ១. សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រជាតិ មានគោលបំណងកំណត់ឱ្យបាននូវការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ សម្រាប់ប្រជាជនរស់នៅតាមតំបន់ជនបទស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០០និងក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៣។ ការផ្គត់ផ្គង់ទឹកជនបទនៅក្នុងផែនការយុទ្ធសាស្ត្រជាតិនេះមានវិសាលភាពនៅតំបន់ជនបទ ដោយមានសហគមន៍ជាអ្នកគ្រប់គ្រងនិងជាម្ចាស់ ហើយការរកប្រាក់ចំណេញមិនមែនជាគោលបំណងជាចម្បង។

ការរៀបចំស្ថាប័ន ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស ព្រមទាំងធនធានផ្សេងៗទៀត ជាការចាំបាច់ដើម្បីផ្តល់សេវានិងលើកកម្ពស់សុខភាពសាធារណៈ ប្រកបដោយនិរន្តរភាព។ គោលបំណងសំខាន់គឺដើម្បីពន្លឿនដំណើរការនេះ ឆ្ពោះទៅសម្រេចបាននូវទស្សនវិស័យរបស់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទឆ្នាំ២០២៥។

ផែនការយុទ្ធសាស្ត្រជាតិនេះ នឹងត្រូវបានប្រើប្រាស់ដោយស្ថាប័នគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ រួមមានស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងផ្នែកឯកជន។

ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទនេះ មានដំណើរការទៅតាមលំដាប់ថ្នាក់ខុសៗគ្នាមួយចំនួនដូចជា កម្រិតគ្រួសារនិងសហគមន៍ កម្រិតថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ។ នៅតាមលំដាប់ថ្នាក់នីមួយៗ មានអ្នកអនុវត្ត ភាគីពាក់ព័ន្ធ ព្រមទាំងបុគ្គលផ្សេងៗគ្នាជាច្រើន ដែលពួកគេម្នាក់ៗមានទស្សនៈនិងមតិយោបល់ផ្សេងៗគ្នា។ ទស្សនៈនិងមតិយោបល់ផ្សេងៗទាំងអស់នេះ បូកបញ្ចូលគ្នាបានធ្វើឱ្យកិច្ចការនេះជាការងារដែលមានលក្ខណៈស្មុគស្មាញ ទាំងគុណតម្លៃ ទាំងការយល់ដឹងពីបញ្ហាប្រឈមប្រព័ន្ធនិងដំណើរការ ក៏ដូចជាការយល់ដឹងពីមធ្យោបាយ ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងមូល ជួយឱ្យប្រជាជននៅតាមជនបទទទួលបាននូវការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យប្រកបដោយនិរន្តរភាព។

យុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈមទាំងនេះ ក៏មានលក្ខណៈស្មុគស្មាញស្រដៀងគ្នាដែរ ។ យើងត្រូវមានសកម្មភាពយុទ្ធសាស្ត្រនិងសកម្មភាពពិស្តារជាច្រើននៅតាមលំដាប់ថ្នាក់ខុសៗគ្នា ដើម្បីដោះស្រាយបញ្ហាប្រឈមនីមួយៗ។ គ្រប់សកម្មភាពទាំងអស់នេះ ទាមទារឱ្យមានកិច្ចសម្របសម្រួល ដើម្បីសម្រេចបាននូវគោលបំណងរួមរបស់ផែនការយុទ្ធសាស្ត្រជាតិនេះ។

ក្រសួងអភិវឌ្ឍន៍ជនបទ បានបង្កើតក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទ ដើម្បីដឹកនាំការរៀបចំធ្វើឯកសារយុទ្ធសាស្ត្រជាតិនេះឡើង។ ការពិគ្រោះយោបល់ រួមបញ្ចូលទាំងការងារចុះផ្ទាល់ក្នុងខេត្តមួយចំនួន ព្រមទាំងសិក្ខាសាលាស្តីពីការវិភាគស្ថានភាព ដោយមានការចូលរួមពីតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ អភិបាលស្រុក មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងអង្គភាពរដ្ឋបាលមូលដ្ឋាន គ្រប់រាជធានី ខេត្ត ក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល ព្រមទាំងផ្នែកឯកជន។ ការពិគ្រោះយោបល់ក៏បានរួមបញ្ចូលនូវសិក្ខាសាលាមួយចំនួន ដោយមានការចូលរួម

ពីអ្នកជំនាញខាងការងារផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទសំខាន់ៗជាច្រើនរូប ដើម្បីដោះស្រាយបញ្ហាជាក់លាក់មួយចំនួន។ ការពិគ្រោះយោបល់ក៏បានរួមបញ្ចូលផងដែរនូវការរាយការណ៍សង្ខេបជូនក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទ។

ផែនការយុទ្ធសាស្ត្រជាតិនេះនឹងត្រូវអនុវត្តជាពីរដំណាក់កាល។ ដំណាក់កាលទី១ពីឆ្នាំ២០១៤-២០១៨។ នៅឆ្នាំ២០១៨នឹងមានការត្រួតពិនិត្យពាក់កណ្ដាលគម្រោងដើម្បីត្រួតពិនិត្យវឌ្ឍនភាពនិងការប្រែប្រួលបើមានការចាំបាច់។ ដំណាក់កាលទី២នឹងអនុវត្តពីឆ្នាំ២០១៩-២០២៥។ ក្នុងអំឡុងឆ្នាំ២០២៥នឹងមានការត្រួតពិនិត្យនិងវាយតម្លៃចុងក្រោយ។

## ២. ចក្ខុវិស័យ

ផែនការយុទ្ធសាស្ត្រជាតិនេះ មានចក្ខុវិស័យធ្វើឱ្យប្រជាជននៅជនបទមានសេវាផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ ប្រកបដោយសមធម៌និងមាននិរន្តរភាព។

## ៣. បេសកកម្ម

ផែនការយុទ្ធសាស្ត្រជាតិនេះ មានបេសកកម្មដើម្បីលើកកម្ពស់សុខភាពសាធារណៈរបស់ប្រជាជនតាមរយៈការអភិវឌ្ឍការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ។

## ៤. គោលបំណងនិងគោលដៅ

### ៤.១. គោលបំណង

ផែនការយុទ្ធសាស្ត្រជាតិនេះ មានគោលបំណងធ្វើឱ្យសេវាទឹកស្អាតនិងអនាម័យនៅជនបទមានភាពប្រសើរឡើង និងប្រកបដោយនិរន្តរភាពនៅឆ្នាំ២០២៥។

### ៤.២. គោលដៅ

ផែនការយុទ្ធសាស្ត្រជាតិនេះ មានគោលដៅបង្កើតនិងបង្កើនការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាបានកំណត់ថានៅឆ្នាំ២០១៥ ប្រជាជននៅជនបទ៥០% នឹងទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អ និងនៅឆ្នាំ២០១៥ ប្រជាជននៅជនបទ៣០% នឹងទទួលបានការលើកកម្ពស់អនាម័យ។ ទស្សនវិស័យនៃការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទបានកំណត់ថានៅឆ្នាំ២០២៥ ប្រជាជនគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព។

## ៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រជាតិនេះ ផ្តល់នូវការតម្រង់ទិសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ផ្នែកឯកជន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងសប្បុរសជន ដើម្បីប្រសិទ្ធភាពនៃការអភិវឌ្ឍការងារផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទ សំដៅលើកកម្ពស់សុខភាពសាធារណៈរបស់ប្រជាជននៅជនបទទូទាំងប្រទេស។

### ៥.១. ការវិភាគជាយុទ្ធសាស្ត្រ

យោងតាមលទ្ធផលជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជា២០០៨ បានបង្ហាញថា អត្រាគ្រួសារដណ្តប់ទឹកស្អាតមានត្រឹមតែ៤១% និងអនាម័យជនបទត្រឹមតែ២៣%ប៉ុណ្ណោះ។ តួលេខនេះបានបញ្ជាក់ថាលទ្ធភាពនៃការទទួលបានសេវាប្រើប្រាស់ទឹកស្អាតនិងអនាម័យនៅជនបទ នៅមានកម្រិតទាបនៅឡើយ ប្រសិនបើ

ប្រៀបធៀបជាមួយបណ្ដាប្រទេសក្នុងតំបន់ដូចគ្នា។ ទន្ទឹមនឹងនោះផងដែរ ការទទួលបានទឹកស្អាតនិងអនាម័យនៅតាមតំបន់ផ្សេងៗនៃប្រទេសកម្ពុជា មានលក្ខណៈមិនដូចគ្នាទេ។ ការទទួលបានទឹកស្អាតនៅបណ្ដាខេត្តជាប់មាត់សមុទ្រមានកម្រិតទាប(២៤,២%) បើធៀបនឹងតំបន់ផ្សេងទៀតដូចជាតំបន់ទំនាបមាន៥១,៥% តំបន់ជុំវិញបឹងទន្លេសាបមាន៣០,៣% តំបន់ភ្នំនិងខ្ពង់រាបមាន៣៥,៩% និងតំបន់ភ្នំពេញមាន៤១,៦%។ រីឯអត្រាគ្របដណ្ដប់អនាម័យនៅបណ្ដាខេត្តតាមតំបន់ភ្នំនិងខ្ពង់រាប មានកម្រិតទាប(១៥,៦%) បើធៀបនឹងតំបន់ផ្សេងទៀតដូចជាតំបន់ទំនាបមាន២៤,៤% តំបន់ជុំវិញបឹងទន្លេសាបមាន២៣,១% តំបន់ឆ្នេរសមុទ្រមាន២៤,២% និងតំបន់ភ្នំពេញមាន៦៧,១%។ បើគ្មានដំណោះស្រាយលើបញ្ហាកង្វះទឹកស្អាតនិងអនាម័យនៅជនបទនោះទេ វានឹងជះឥទ្ធិពលដល់បញ្ហាមួយចំនួន ដូចជាបញ្ហាសុខភាព ការអប់រំ និងភាពក្រីក្រ។ បញ្ហាសុខភាពដែលបណ្ដាលមកពីកង្វះទឹកស្អាតនិងអនាម័យ បានបង្កឱ្យមានជំងឺរាក ជំងឺគ្រុន កង្វះអាហារូបត្ថម្ភ និងជំងឺឆ្លងផ្សេងៗ។ ការសិក្សារបស់កុមារបានថយចុះដោយសារតែសុខភាពទន់ខ្សោយ ជាពិសេសការបោះបង់ចោលការសិក្សារបស់ក្មេងស្រី។ ថវិកាចំណាយលើការប្រើប្រាស់ទឹកមានកម្រិតខ្ពស់ លទ្ធភាពរកប្រាក់ចំណូលបានកាត់បន្ថយដោយសារសុខភាពទន់ខ្សោយ ខាតពេលវេលាក្នុងការរកទឹក និងបាត់បង់ឱកាសធ្វើអាជីវកម្មផ្សេងៗសម្រាប់រកប្រាក់ចំណូល។ លើសពីនេះ ស្ត្រីជាអ្នកទទួលបន្ទុកធ្ងន់ ដែលធ្វើឱ្យពួកគេមានឱកាសតិចតួចសម្រាប់ប្រកបការងាររកកម្រៃ។ ប្រជាជនដែលមានពិការភាព ក៏ជាអ្នកប្រឈមនឹងការលំបាកផងដែរ។ បញ្ហាទាំងអស់នេះមានទំហំធំធេងនិងជះឥទ្ធិពលដល់ជីវភាពប្រជាជនរស់នៅជនបទ។

បញ្ហាកង្វះទឹកស្អាតនិងអនាម័យបណ្ដាលមកពីកត្តាជាច្រើន ដែលក្នុងនោះរួមមាន សមត្ថភាពក្នុងការគ្រប់គ្រងនិងផ្ដល់សេវា ការបែងចែកតួនាទី តាមប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការ ការចូលរួមរបស់ផ្នែកឯកជន ការតាមដាន បច្ចេកវិទ្យា ហិរញ្ញប្បទាន និងភាពក្រីក្រ។

សមត្ថភាពក្នុងការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទនៅមានកម្រិត។ ដំណើរការវិវត្តនៃប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការ និងការរៀបចំរចនាសម្ព័ន្ធថ្មី តួនាទី និងការទទួលខុសត្រូវនាពេលអនាគតរបស់ផ្នែកនេះ នៅមិនទាន់មានភាពច្បាស់លាស់។

ម្យ៉ាងទៀត ការបង្កើនសមត្ថភាពធនធានមនុស្ស ដើម្បីសម្របសម្រួលនិងផ្ដល់សេវាកម្មទាំងនេះ គឺជាបញ្ហាប្រឈមមួយ។ ប្រជាជននៅតាមជនបទស្ទើរតែទាំងអស់ទាមទារឱ្យមានការណែនាំឡើងវិញ ក្នុងការអនុវត្តការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ។

ការរួមចំណែករបស់ផ្នែកឯកជននៅមានកម្រិតនៅឡើយ ដោយសារមានកត្តាមួយចំនួន ដូចជាកង្វះឥណទាន ហានិភ័យនៃការវិនិយោគ កង្វះការអភិវឌ្ឍជំនាញអាជីវកម្ម ការប្រកួតប្រជែងមិនទាន់បានល្អ ព្រមទាំងប្រព័ន្ធនិយតកម្មទន់ខ្សោយ។

ប្រព័ន្ធតាមដានត្រួតពិនិត្យសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ មិនមានការប្រើប្រាស់បទដ្ឋានតែមួយសម្រាប់ផ្នែកពាក់ព័ន្ធទេ។ ករណីនេះបង្កឱ្យមានការលំបាកក្នុងការតាមដានត្រួតពិនិត្យ។ មានជម្រើសបច្ចេកវិទ្យាតិចតួចសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត ជាពិសេសនៅតំបន់ខ្វះប្រភពទឹក។ រីឯបង្គន់អនាម័យ ក៏មានគំរូបង្គន់តម្លៃថោកតិចតួចដែលអាចឱ្យប្រជាជនក្រីក្រមានលទ្ធភាពទិញប្រើប្រាស់ដោយខ្លួនឯងបាន។ រហូតមកដល់ពេលនេះ នៅពុំទាន់មានដំណោះស្រាយទៅលើការប្រើប្រាស់បង្គន់ប្រកបដោយនិរន្តរភាព នៅតំបន់ដែលមានទឹកជំនន់និងនៅតាមភូមិដែលរស់នៅលើទឹកជាប្រចាំនៅឡើយ។ តាមការប៉ាន់ស្មានបានបង្ហាញថា គម្លាតហិរញ្ញប្បទានសម្រាប់សម្រេចឱ្យបានគោលដៅក្នុងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ នៅមានទំហំធំធេង។

ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ មានការពាក់ព័ន្ធផ្ទាល់ទៅនឹងចង្កោមអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ដូចបានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការវិនិយោគទុននិងការយកចិត្តទុកដាក់លើចំណុចគោលដៅ នឹងត្រូវបានផ្តោតទៅរកប្រជាជននិងតំបន់ដែលមិនទាន់មានសេវាផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ ជាពិសេសផ្តោតទៅរកតំបន់ដែលមានអត្រាភាពក្រីក្រខ្ពស់។

### ៥.២. ទិសដៅជាយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រជាតិនេះ នឹងត្រូវអនុវត្តពីឆ្នាំ២០១៨ដល់ឆ្នាំ២០២៥ ដោយផ្តោតទៅលើទិសដៅសំខាន់ៗដូចខាងក្រោម៖

- បង្កើតយន្តការសម្រាប់បង្កលក្ខណៈក្នុងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ ប្រកបដោយនិរន្តរភាព
- បង្កើនហិរញ្ញប្បទានសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
- ជំរុញនិងលើកទឹកចិត្តប្រជាជននៅជនបទឱ្យទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត ប្រកបដោយនិរន្តរភាព
- ជំរុញនិងលើកទឹកចិត្តប្រជាជននៅជនបទឱ្យទទួលបានការលើកកម្ពស់អនាម័យ ប្រកបដោយនិរន្តរភាព
- ជំរុញនិងលើកទឹកចិត្តប្រជាជនឱ្យមានការផ្លាស់ប្តូរឥរិយាបថ ក្នុងការប្រើប្រាស់ទឹកស្អាតនិងអនាម័យប្រកបដោយនិរន្តរភាព

### ៥.៣. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបានទិសដៅទាំង៥ខាងលើ ផែនការយុទ្ធសាស្ត្រជាតិនេះទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល សាធារណជន ព្រមទាំងផ្នែកឯកជន ក្នុងការពង្រឹងធនធានមនុស្ស ពង្រឹងការគ្រប់គ្រង ពង្រឹងតួនាទីនិងការទទួលខុសត្រូវនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ បង្កើតបរិយាកាសសមស្របសម្រាប់ផ្នែកឯកជន ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ បង្កើតជម្រើសបច្ចេកវិទ្យាសមស្របមានតម្លៃថោក និងជំរុញឱ្យមានការចូលរួមពីគ្រួសារក្រីក្រ ដោយយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចខាងក្រោម៖

#### ៥.៣.១. បង្កើតយន្តការសម្រាប់បង្កលក្ខណៈ ក្នុងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ ប្រកបដោយនិរន្តរភាព

- ពង្រឹងការគ្រប់គ្រងផ្នែកផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
- អភិវឌ្ឍធនធានមនុស្សនិងសមត្ថភាព
- អភិវឌ្ឍផ្នែកឯកជន
- ធ្វើផែនការនិងប្រព័ន្ធគ្រប់គ្រងព័ត៌មាន
- វាយតម្លៃនិងរៀនសូត្រ
- ស្រាវជ្រាវ អភិវឌ្ឍ និងច្នៃប្រឌិត
- បង្កើតនិងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនង
- ផ្តល់អាទិភាពដល់តំបន់ក្រីក្រ តំបន់ដែលមានជនជាតិដើមភាគតិច និងតំបន់ដែលងាយរងគ្រោះ

- បញ្ហាបយេនឌ័រនៅក្នុងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
- សិក្សាអំពីទំនាក់ទំនងរវាងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ និងផលប៉ះពាល់បរិស្ថាន និងកសាងគោលការណ៍ណែនាំដើម្បីដោះស្រាយ
- គ្រប់គ្រងនិងកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។

៥.៣.២. បង្កើនហិរញ្ញប្បទានសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ

- កៀរគរឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដូចជារាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ សង្គមស៊ីវិល ផ្នែកឯកជន និងសាធារណជនទូទៅ ដោយយកចិត្តទុកដាក់ក្នុងការផ្តល់ហិរញ្ញប្បទាន
- បង្កើតមូលនិធិហិរញ្ញវត្ថុសម្រាប់ផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់
- បង្កើតយន្តការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យសម្រាប់អ្នកក្រីក្រ។

៥.៣.៣. ជំរុញនិងលើកទឹកចិត្តប្រជាជននៅជនបទឱ្យទទួលបានការផ្គត់ផ្គង់ទឹកស្អាត ប្រកបដោយនិរន្តរភាព

- ផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មីនិងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់
- អភិវឌ្ឍបច្ចេកវិទ្យានិងសេវាកម្មសមស្របតាមបទដ្ឋានគុណភាពទឹក
- ពង្រឹងប្រព័ន្ធប្រតិបត្តិការនិងការថែទាំ
- បង្កលក្ខណៈឱ្យមានទីផ្សារសម្រាប់ផលិតផលទឹកស្អាត។

៥.៣.៤. ជំរុញនិងលើកទឹកចិត្តប្រជាជននៅជនបទឱ្យទទួលបានការលើកកម្ពស់អនាម័យ ប្រកបដោយនិរន្តរភាព

- បង្កើនលទ្ធភាពទទួលបានអនាម័យ
- ពង្រឹងប្រព័ន្ធប្រតិបត្តិការនិងការថែទាំ
- បង្កើតនូវបទដ្ឋានអនាម័យសម្រាប់សាលារៀន គ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀតនៅតាមជនបទ។

៥.៣.៥. ជំរុញនិងលើកទឹកចិត្តប្រជាជនឱ្យមានការផ្លាស់ប្តូរឥរិយាបថ ក្នុងការប្រើប្រាស់ទឹកស្អាត និងអនាម័យប្រកបដោយនិរន្តរភាព ដោយធ្វើការផ្សព្វផ្សាយ អប់រំ និងបណ្តុះបណ្តាលស្តីពីការផ្លាស់ប្តូរឥរិយាបថអនាម័យឱ្យបានជាប្រចាំ។

## ៦. សកម្មភាពការងារ

ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ គឺចាំបាច់ត្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីផ្នែកសាធារណៈ ផ្នែកឯកជន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល សប្បុរសជន និងសហគមន៍។

**៦.១- បង្កើតយន្តការសម្រាប់បង្កលក្ខណៈក្នុងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទប្រកបដោយនិរន្តរភាព**

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

### ៦.១.១. គ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ

- តាមដានត្រួតពិនិត្យការរីកចម្រើនសកម្មភាពនិងសមិទ្ធផលរបស់ផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
- ពង្រឹងយន្តការនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ដោយមានការគាំទ្រពីរដ្ឋបាលថ្នាក់ក្រោមជាតិ
- ដាក់ឱ្យប្រើប្រាស់សេចក្តីប្រកាសដែលកំណត់ពីតួនាទីរបស់ស្ថាប័នពាក់ព័ន្ធក្នុងផ្នែកនេះ
- បង្កើតនីតិវិធីដើម្បីធ្វើឱ្យអាជ្ញាធរមូលដ្ឋានមានគណនេយ្យភាពចំពោះសហគមន៍ ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យ រួមទាំងការប្រើប្រាស់យន្តការសហគមន៍ ដើម្បីតាមដាននិងត្រួតពិនិត្យនៃការផ្តល់សេវាកម្ម
- បង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងមួយសម្រាប់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ដើម្បីស្វែងរកព័ត៌មានទទួលព័ត៌មាន និងព័ត៌មានត្រឡប់ពីសហគមន៍ គ្រួសារ និងក្រុមប្រឹក្សាឃុំ សង្កាត់ រួមទាំងប្រព័ន្ធតាមដានប្រៀបធៀបការអនុវត្តរវាងថ្នាក់ស្រុកនិងសហគមន៍នីមួយៗ
- បង្កើតគោលការណ៍ណែនាំសម្រាប់រដ្ឋបាលមូលដ្ឋាន អំពីរបៀបក្នុងការធានាឱ្យបាននូវគណនេយ្យភាពចំពោះថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បង្កើតគោលការណ៍ណែនាំនិងនីតិវិធីថ្មីៗ ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ តាមតម្រូវការក្នុងផ្នែកផ្សេងៗនៃផែនការយុទ្ធសាស្ត្រជាតិនេះ
- ពិនិត្យឡើងវិញគោលការណ៍ណែនាំនិងនីតិវិធីផ្សេងៗដែលមានស្រាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ ហើយកែសម្រួល បើមានការចាំបាច់
- ចងក្រងឯកសារគោលការណ៍ណែនាំនិងផ្សព្វផ្សាយទៅឱ្យស្ថាប័នថ្នាក់ជាតិ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវា ក្រុមប្រឹក្សាស្រុក ខណ្ឌ និងឃុំ សង្កាត់ ព្រមទាំងសហគមន៍អ្នកប្រើប្រាស់
- តាមដានត្រួតពិនិត្យការប្រើប្រាស់និងប្រសិទ្ធភាពនៃគោលការណ៍ណែនាំនិងការកែសម្រួល ប្រសិនបើចាំបាច់។

### ៦.១.២. ការអភិវឌ្ឍធនធានមនុស្សនិងសមត្ថភាព

- ពង្រឹងសមត្ថភាពមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុកនិងអ្នកពាក់ព័ន្ធ
- រៀបចំផែនការលម្អិតសម្រាប់អភិវឌ្ឍន៍សមត្ថភាពដើម្បីកំណត់៖
    - បទពិសោធនិងជំនាញសម្រាប់កិច្ចការចាំបាច់ នៅថ្នាក់ខេត្តនិងថ្នាក់ស្រុក
    - សមត្ថភាពនិងចំនួនបុគ្គលិកដែលមានស្រាប់
    - ការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិកដែលត្រូវបំពេញតួនាទី
    - ថវិកាសម្រាប់ការអនុវត្តផែនការ
- សម្របសម្រួលការធ្វើផែនការអភិវឌ្ឍន៍សមត្ថភាពជាមួយនឹងវិស័យដទៃៗទៀត និងដំណើរការវិមជ្ឈការនិងវិសហមជ្ឈការ ដើម្បីធានាថាការអភិវឌ្ឍសមត្ថភាពទាំងអស់នោះ អាចធ្វើទៅបាន
- អនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពដែលបានបង្កើតរួច
- បង្កើតវគ្គបណ្តុះបណ្តាលរយៈពេលខ្លី សម្រាប់មន្ត្រីថ្នាក់ក្រោមជាតិនិងបុគ្គលិកពីស្ថាប័នពាក់ព័ន្ធនានា។

### ៦.១.៣. ការអភិវឌ្ឍផ្នែកឯកជន

- បង្កើតនីតិវិធីបន្ថែមចំនួនបី ដើម្បីធានាឱ្យមានការគោរពកិច្ចសន្យានិងនីតិវិធីលទ្ធកម្ម៖

- ធ្វើឱ្យក្រុមប្រើប្រាស់ទឹកនិងអនាម័យមានតួនាទីក្នុងកិច្ចសន្យា។ ដូច្នេះ កិច្ចសន្យានេះ គឺធ្វើឡើងរវាងអាជ្ញាធរមានសមត្ថកិច្ច រួមគ្នាជាមួយនឹងក្រុមប្រើប្រាស់ទឹកនិងអនាម័យ ជាភាគីម្ខាង ជាមួយភាគីម្ខាងទៀតដែលជាក្រុមហ៊ុនឯកជន
- យោងទៅតាមដំណើរការដេញថ្លៃ ត្រូវផ្សព្វផ្សាយទៅឱ្យសហគមន៍ប្រើប្រាស់ទឹកនិងអនាម័យ អំពីការដេញថ្លៃឱ្យស្របតាមនីតិវិធីលទ្ធកម្មសាធារណៈ
- ពេលកិច្ចសន្យានៃការសាងសង់ត្រូវបានបញ្ចប់ ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានផ្លូវការជាសាធារណៈ អំពីគណនីរបស់គម្រោងដល់សហគមន៍ ដោយភ្ជាប់ជាមួយនូវព័ត៌មានលម្អិតពីថវិកាក្នុងគម្រោង ដែលបានចំណាយក្នុងការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាព។

- រៀបចំនិងចងក្រងផ្សព្វផ្សាយគោលការណ៍ណែនាំស្ដីពីការទទួលខុសត្រូវ គណនេយ្យភាព ការព្យាករ និងតម្លាភាពសម្រាប់ផ្នែកឯកជន
- ផ្សព្វផ្សាយគោលការណ៍ណែនាំនេះ ទៅការិយាល័យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ដែលពាក់ព័ន្ធនឹងផ្នែកនេះ និងក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្សព្វផ្សាយគោលការណ៍ណែនាំខាងលើ ទៅសហគ្រាសធុនតូច និងមធ្យមទាំងអស់ដែលមានចំណាប់-អារម្មណ៍ក្នុងការផ្ដល់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
- កំណត់រកនិងរក្សាឱ្យមានធនធានជាមូលធនសម្រាប់ការវិនិយោគ តាមរយៈស្ថាប័នមីក្រូហិរញ្ញវត្ថុ
- កំណត់រកស្ថាប័នបណ្តុះបណ្តាលសមស្រប និងបង្កើតកម្មវិធីបណ្តុះបណ្តាល
- ផ្ដល់វគ្គបណ្ដុះបណ្ដាលដល់សហគ្រាសខ្នាតតូចនិងមធ្យមនៅថ្នាក់មូលដ្ឋាន។

**៦.១.៤. ការធ្វើផែនការ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន**

- ធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងព័ត៌មានបច្ចុប្បន្នជាមួយនឹងទិន្នន័យផ្សេងៗ សម្រាប់បង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមមួយ
- ធ្វើឱ្យប្រព័ន្ធគ្រប់គ្រងព័ត៌មានអាចប្រើបានដោយអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងផ្នែកនេះ និងដាក់វាទៅក្នុងគេហទំព័រ និងតាមរយៈមធ្យោបាយផ្សេងៗ សម្រាប់ប្រាស្រ័យទាក់ទងដល់អ្នកពាក់ព័ន្ធដែលគ្មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត
- ធានាថាទិន្នន័យទាំងអស់អំពីហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័ន និងកត្តាសង្គមត្រូវបានប្រមូល ហើយចែកចេញជាផ្នែកស្ត្រី បុរស កុមារ ជនពិការ និងជនជាតិដើមភាគតិច។

**៦.១.៥. ការវាយតម្លៃនិងការរៀនសូត្រ**

- បង្កើតប្រព័ន្ធចែករំលែកលទ្ធផលនៃការវាយតម្លៃ ក្រោមការគ្រប់គ្រងរបស់ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ
- ធ្វើការវាយតម្លៃនិងផ្សព្វផ្សាយនូវលទ្ធផលឱ្យបានទូលំទូលាយក្នុងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ និងការសិក្សាលើទិដ្ឋភាពជាក់លាក់និងវិធីសាស្ត្រមួយចំនួនក្នុងផ្នែកនេះ។

**៦.១.៦. ការស្រាវជ្រាវនិងការអភិវឌ្ឍ**

- បង្កើតនីតិវិធីជាលក្ខណៈប្រព័ន្ធសម្រាប់អនុវត្តការធ្វើពិសោធន៍ ការអនុម័ត និងផ្សព្វផ្សាយអំពីវិធីសាស្ត្រ និងលទ្ធផលអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ
- បង្កើតគណៈកម្មាធិការសម្រាប់ណែនាំនិងអនុម័តក្នុងការងារនេះ។

### ៦.១.៧. ទំនាក់ទំនង

- បង្កើតនិងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនង ដើម្បីដោះស្រាយបញ្ហាផ្សេងៗ រួមមាន៖
  - លើកកម្ពស់វិស័យនេះ តាមរយៈការផ្សព្វផ្សាយពីឥទ្ធិពលរបស់វិស័យនេះទៅលើទិដ្ឋភាពនយោបាយជាអាទិភាពនានា ដូចជាការអភិវឌ្ឍសុខភាពនិងសេដ្ឋកិច្ច
  - ធ្វើឱ្យវិស័យនេះមានការទាក់ទាញចំពោះសារព័ត៌មាន
  - ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្ររបស់វិស័យនេះ ទាំងនៅក្នុងនិងក្រៅផ្នែកផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
  - បង្កើនប្រសិទ្ធភាពរបស់ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ
  - កំណត់ទិន្នន័យសំខាន់ៗនិងព័ត៌មានដែលចាំបាច់។

### ៦.១.៨. ភាពក្រីក្រ ជនជាតិដើមភាគតិច ភាពងាយរងគ្រោះ

- ផ្តល់អាទិភាពដល់តំបន់ក្រីក្របំផុតនិងតំបន់ដែលពុំធ្លាប់មានការគាំទ្រ ដើម្បីផ្តល់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
- កំណត់រកស្រុក ខណ្ឌ និងឃុំ សង្កាត់ក្រីក្របំផុតនៅក្នុងរាជធានី ខេត្ត និងគ្រួសារក្រីក្របំផុតនៅក្នុងភូមិ ដោយយោងតាមបញ្ជីកំណត់គ្រួសារក្រីក្រ ដែលត្រូវបានបង្កើតឡើងនិងរក្សាដោយមន្ទីរផែនការខេត្ត
- ការបង្កើតនិងការផ្តល់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ ត្រូវគោរពតាមច្បាប់ស្តីពីកិច្ចគាំពារនិងការលើកកម្ពស់សិទ្ធិជនពិការ
- គម្រោងនិងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទទាំងអស់ នឹងត្រូវពិចារណាលើសេចក្តីត្រូវការរបស់ជនពិការ នៅគ្រប់ដំណាក់កាលនៃការរៀបចំនិងអនុវត្តគម្រោងនិងកម្មវិធី
- អង្គការជនពិការនឹងត្រូវបានបញ្ចូល ឬធ្វើជាតំណាងនៅក្នុងដំណើរការពិគ្រោះយោបល់គណៈកម្មការ ឬក្រុមប្រឹក្សាផ្តល់យោបល់។

### ៦.១.៩. ការបញ្ជ្រាបយេនឌ័រ

- ពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នកម្មផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ
- ពិនិត្យឡើងវិញគ្រប់គោលការណ៍ណែនាំនិងនីតិវិធីដែលមានស្រាប់ និងត្រូវបង្កើតនៅពេលខាងមុខរបស់ផ្នែកផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ ដើម្បីធានាថាគោលការណ៍ណែនាំនិងនីតិវិធីទាំងនេះបានបញ្ជាក់និងណែនាំអំពីបញ្ហាយេនឌ័រ
- បង្កើតវគ្គតម្រង់ទិសអំពីយេនឌ័រសម្រាប់មន្ត្រីរដ្ឋាភិបាល ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអ្នកផ្តល់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
- រៀបចំវគ្គតម្រង់ទិសអំពីយេនឌ័រសម្រាប់ភាគីពាក់ព័ន្ធទាំងឡាយ។

### ៦.១.១០. បរិស្ថាន

- ធ្វើការសិក្សាពីកម្រិតយល់ដឹងនិងទំនាក់ទំនងរវាងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ និងផលប៉ះពាល់បរិស្ថាន រួមទាំងការគ្រប់គ្រងធនធានទឹកចម្រុះនិងផលប៉ះពាល់ដល់សុខភាព
- កសាងគោលការណ៍ណែនាំនិងនីតិវិធី ដើម្បីដោះស្រាយផលប៉ះពាល់បរិស្ថានដែលពាក់ព័ន្ធ ក្នុងការផ្តល់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ។

**៦.១.១១. ការគ្រប់គ្រងនិងការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ**

- សម្របសម្រួលជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នូវវិធានការត្រៀមបង្ការនិងគ្រប់គ្រងគ្រោះមហន្តរាយ
- កែសម្រួលលក្ខណៈបច្ចេកទេស សម្រាប់សំណង់ផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទក្នុងតំបន់ងាយរងគ្រោះដោយទឹកជំនន់
- រៀបចំផែនទីចង្អុលបង្ហាញពីតំបន់ងាយរងគ្រោះដោយទឹកជំនន់ តំបន់រាំងស្ងួត និងបង្កើតវិធានការកាត់បន្ថយផលប៉ះពាល់។

**៦.២. បង្កើនហិរញ្ញប្បទានសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ**

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

**៦.២.១. ហិរញ្ញប្បទាននៃការចំណាយទុនដើម**

- រៀបចំផែនការវិនិយោគលើផ្នែកផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
- ត្រូវមានការបង្កើននូវមូលនិធិគាំទ្រ ដោយបង្ហាញពីផលចំណេញសេដ្ឋកិច្ចនិងសង្គមកិច្ចដែលបានមកពីការវិនិយោគលើការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ
- ពិនិត្យឡើងវិញលើសមាមាត្រនៃការចូលរួមបដិភាគពីសហគមន៍ក្នុងខេត្តនិងស្រុកនីមួយៗ ដោយបង្កើតនីតិវិធីនិងលក្ខណវិនិច្ឆ័យ សម្រាប់កំណត់អត្រាចូលរួមបដិភាគរបស់សហគមន៍និងកំណត់អត្រាចូលរួមបដិភាគនៅតាមមូលដ្ឋាន ដោយអនុលោមតាមនីតិវិធីដែលបានបង្កើតឡើង
- បង្កើតក្រុមការងារដើម្បីដឹកនាំនិងណែនាំការបង្កើតជម្រើសយន្តការនានាសម្រាប់ការធ្វើហិរញ្ញប្បទានផ្នែកអនាម័យ
- បង្កើតឱ្យមានការសាកល្បងដកពិសោធយន្តការផ្តល់ហិរញ្ញប្បទាន
- តាមដានត្រួតពិនិត្យប្រសិទ្ធភាពនៃយន្តការនោះ ធ្វើការវាយតម្លៃប្រៀបធៀបយន្តការផ្តល់ហិរញ្ញប្បទានទាំងឡាយបន្ទាប់ពីដាក់ឱ្យអនុវត្តមួយរយៈកន្លងមក
- បង្កើតឱ្យមានគោលការណ៍ណែនាំស្តីពីយន្តការប្រកបដោយប្រសិទ្ធភាព សមស្របសម្រាប់ក្រុមគោលដៅផ្សេងៗ
- ប៉ាន់ស្មានថវិកាចំណាយលើផែនការអភិវឌ្ឍន៍សមត្ថភាពនិងលើការអភិវឌ្ឍផ្នែកឯកជន
- ស្វែងរកដៃគូអភិវឌ្ឍ ដើម្បីចូលរួមនិងផ្តល់មូលនិធិ គាំទ្រឱ្យមានការបណ្តុះបណ្តាលផ្នែកឯកជនក្នុងការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ។

**៦.២.២. ហិរញ្ញប្បទាននៃការចំណាយចរន្ត**

- ចំណាយសម្រាប់ប្រតិបត្តិការលើការផ្គត់ផ្គង់ទឹកស្អាត រួមទាំងការទូទាត់ថ្លៃចំណាយលើបុគ្គលិកឬអ្នកម៉ៅការ ចំណាយលើការជួសជុល និងការថែទាំ ព្រមទាំងគ្រឿងបន្លាស់ និងការចូលរួមបដិភាគដល់ប្រព័ន្ធទ្រទ្រង់ការថែទាំ
- បង្កើតនិងគ្រប់គ្រងមូលនិធិថែទាំ តាមរយៈការចូលរួមបដិភាគជាប្រចាំពីគ្រួសារអ្នកប្រើប្រាស់
- ក្រុមគ្រួសារនីមួយៗអាចចូលរួមជាថវិកាបដិភាគ លើការប្រើប្រាស់និងការថែទាំបង្គន់អនាម័យរបស់គេផ្ទាល់ រួមមានការគ្រប់គ្រងកាកសំណល់លាមកនិងការស្តារយកកាកសំណល់ទាំងនោះចេញ

- រៀបចំថវិកានិងបែងចែក ព្រមទាំងផ្តល់មូលនិធិសម្រាប់ចំណាយចន្លោលើការសម្របសម្រួលនិងត្រួតពិនិត្យការផ្តល់សេវា ដោយអនុលោមតាមវដ្តនៃការគ្រប់គ្រងហិរញ្ញវត្ថុនាពេលបច្ចុប្បន្ននិងអនាគត។

**៦.៣- ជំរុញនិងលើកទឹកចិត្តប្រជាជននៅជនបទឱ្យទទួលបានការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយនិរន្តរភាព**

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

**៦.៣.១- ការទទួលបានការផ្គត់ផ្គង់ទឹកស្អាត**

- រៀបចំបញ្ជីសារពើភណ្ឌនៃការផ្គត់ផ្គង់ទឹកស្អាត និងភាពខ្វះចន្លោះផ្សេងៗនៅថ្នាក់ស្រុក ហើយចងក្រងព័ត៌មានទាំងនេះនៅថ្នាក់ខេត្តនិងថ្នាក់ជាតិ
- គ្រប់គ្រងការប្រើប្រាស់ប្រភពទឹកតាមផ្ទះឱ្យបានត្រឹមត្រូវ ដោយយោងទៅតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ
- កំណត់ការគាំទ្រដែលផ្តល់ដោយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល
- ជំរុញឱ្យមានដំណើរការដាក់ពាក្យស្នើសុំហេដ្ឋារចនាសម្ព័ន្ធសាងសង់ថ្មីសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត
- ផ្តល់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ថ្មី
- ជំរុញឱ្យមានដំណើរការដាក់ពាក្យស្នើសុំសម្រាប់ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធមានស្រាប់
- រៀបចំសហគមន៍សម្រាប់គ្រប់គ្រងការសាងសង់ ប្រតិបត្តិការ និងថែទាំការផ្គត់ផ្គង់ទឹកស្អាត
- ត្រួតពិនិត្យគុណភាពសំណង់ថ្មី
- ធ្វើការសិក្សានិងត្រួតពិនិត្យដើម្បីកំណត់ទំហំនិងមូលហេតុនៃការខូចខាតកន្លងមក និងដើម្បីកំណត់ពីតម្លៃដើម្បីប្រៀបធៀបសម្រាប់ការជួសជុលឬការសាងសង់ថ្មី
- បង្កើតនីតិវិធីនិងគោលការណ៍ណែនាំស្តីពីការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ដែលសំដៅទៅលើមូលហេតុនៃការខូចខាតពីមុន
- ត្រួតពិនិត្យគុណភាពនៃការស្តារឡើងវិញ
- ផ្តល់មូលនិធិលើថ្លៃទុនដើមសម្រាប់ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើការសិក្សានិងត្រួតពិនិត្យលើបច្ចេកវិទ្យាផ្គត់ផ្គង់ទឹកនៅតំបន់ខ្វះប្រភពទឹកនិងតំបន់ទទួលរងផលប៉ះពាល់ដោយសារធាតុអាសេនិក។ ការសិក្សាស្រាវជ្រាវនេះនឹងរួមបញ្ចូលទាំងការត្រួតពិនិត្យឡើងវិញនូវភាពសមស្របនៃបច្ចេកវិទ្យាសម្រាប់ស្ត្រីដែលជាអ្នកប្រើប្រាស់ និងបច្ចេកវិទ្យានានាដែលកំពុងប្រើប្រាស់តាមបណ្តាប្រទេសនានា
- ធ្វើការសិក្សានិងត្រួតពិនិត្យបច្ចេកទេសផ្គត់ផ្គង់ទឹកស្អាត សម្រាប់បម្រើសេចក្តីត្រូវការពិសេសរបស់សង្គម រួមមានអ្នកប្រើប្រាស់ជាជនពិការ ស្ត្រី និងកុមារ
- អនុវត្តការសិក្សានិងត្រួតពិនិត្យ អភិវឌ្ឍ និងពិសោធសាកល្បង
- បង្កើតប្រព័ន្ធច្បាស់លាស់មួយ សម្រាប់បន្ថែមតម្លៃនៃការធ្វើការនៅតំបន់ដាច់ស្រយាល និងសម្រាប់រួមចំណែកក្នុងការខូចខាតដែលនឹងអាចកើតមានឡើង ដើម្បីជាការលើកទឹកចិត្តដល់ផ្នែកឯកជនឱ្យធ្វើការនៅតំបន់ដាច់ស្រយាល។ ប្រព័ន្ធនេះនឹងជួយក្នុងការចែករំលែកហានិភ័យទាំងឡាយជាមួយភាគីពាក់ព័ន្ធផ្សេងៗ។ ការលើកទឹកចិត្តដល់អ្នកវិនិយោគឯកជនទាំងនេះ គឺជាការសមស្របសម្រាប់ទូទាត់ជាមួយនឹងហានិភ័យទាំងឡាយដែលពួកគេជួបប្រទះ។

### ៦.៣.២. ការអនុវត្តតាមបទដ្ឋានគុណភាពទឹក

- ទទួលយកនូវទស្សនៈ ផែនការសុវត្ថិភាពទឹកសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា និងរៀបចំគោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹក សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ រួមមានផែនការសុវត្ថិភាពទឹកទូទៅ ផ្អែកតាមឯកសារណែនាំស្តីពីផែនការសុវត្ថិភាពទឹកដែលរៀបចំដោយអង្គការសុខភាពពិភពលោក
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗនឹងបង្កើតផែនការសុវត្ថិភាពទឹកសម្រាប់តំបន់របស់ខ្លួន ដែលជាផ្នែកមួយនៃប្រព័ន្ធតាមដានគុណភាពទឹក
- បង្កើតនីតិវិធីមួយសម្រាប់ធ្វើសេចក្តីសម្រេចចិត្តនិងសកម្មភាពមួយចំនួន ដើម្បីឆ្លើយតបទៅនឹងប្រភពទឹកដែលមិនសមស្របតាមបទដ្ឋានស្តង់ដា រួមទាំងការត្រួតពិនិត្យប្រភពទឹកផ្សេងៗ
- ផ្សព្វផ្សាយនិងត្រួតពិនិត្យវាយតម្លៃលើប្រសិទ្ធភាពនៃគោលការណ៍ណែនាំស្តីពីការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន ហើយកែលម្អគោលការណ៍ណែនាំនេះ ប្រសិនបើមានការចាំបាច់។

### ៦.៣.៣. ប្រតិបត្តិការនិងការថែទាំ

- បង្កើតប្រព័ន្ធទ្រទ្រង់ការថែទាំ ដែលរួមមានការត្រួតពិនិត្យតាមដានកម្រិតកម្ពស់ទឹកក្រោមដី
- បង្កើតប្រព័ន្ធទ្រទ្រង់ការថែទាំនៅថ្នាក់ស្រុកនីមួយៗ និងរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកដែលបានចាត់តាំង។

## ៦.៤. ជំរុញនិងលើកទឹកចិត្តប្រជាជននៅជនបទឱ្យទទួលបានការលើកកម្ពស់អនាម័យប្រកបដោយនិរន្តរភាព

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

### ៦.៤.១- ការបង្កើនលទ្ធភាពទទួលបានអនាម័យ

- ធ្វើការផ្សព្វផ្សាយនិងវាយតម្លៃវិធីសាស្ត្រនានា ដូចជាសហគមន៍ដឹកនាំអនុវត្តន៍អនាម័យ ដើម្បីផ្លាស់ប្តូរទម្លាប់អនាម័យផ្ទាល់ខ្លួន
- អនុវត្តវិធីសាស្ត្រនានាដើម្បីជំរុញឱ្យសហគមន៍និងគ្រួសារនីមួយៗផ្លាស់ប្តូរទម្លាប់ ក្នុងការឈានទៅរកការប្រើប្រាស់បង្គន់អនាម័យ
- លើកស្ទួយផលិតផលផ្នែកអនាម័យ នៅតាមទីផ្សារ នៅតាមមូលដ្ឋាន តាមរយៈដំណើរការទីផ្សារសង្គម
- បង្កើតឱ្យមានផលិតផលនិងការលើកកម្ពស់អនាម័យនៅតាមស្រុក ឃុំ និងសហគមន៍ តាមរយៈការកសាងសមត្ថភាពជាងសំណង់និងទីផ្សារក្នុងមូលដ្ឋាន
- ធ្វើការសិក្សានិងត្រួតពិនិត្យដើម្បីកំណត់នូវជម្រើសបង្គន់អនាម័យដែលមានតម្លៃថោក និងផ្សព្វផ្សាយប្លង់គំរូបង្គន់ដែលសមស្រប សម្រាប់ប្រើប្រាស់នៅសហគមន៍
- ធ្វើការសិក្សានិងត្រួតពិនិត្យដើម្បីកំណត់ប្រភេទបង្គន់និងធ្វើតេស្តសាកល្បងលើប្រភេទបង្គន់ដែលសមស្រប សម្រាប់ភូមិលិចទឹកនិងភូមិបណ្តែតទឹក។

### ៦.៤.២. ប្រតិបត្តិការនិងការថែទាំ

- បង្កើតនីតិវិធីសម្រាប់ការគ្រប់គ្រងកាកសំណល់នៃអាងស្តុកលាមកនិងស្តារយកកាកសំណល់ចេញ
- បង្កើតប្រព័ន្ធសម្រាប់ទុកដាក់កាកសំណល់ ឬការប្រើប្រាស់ឡើងវិញនូវកាកសំណល់នៃអាងស្តុកលាមកពីបង្គន់

- បង្កើតសេវាស្តារសម្អាតអាងស្តុកលាមកនិងរណ្តៅបង្គន់ រួមជាមួយនឹងការបណ្តុះបណ្តាលពីការទុកដាក់កាកសំណល់បង្គន់ប្រកបដោយសុវត្ថិភាព។

**៦.៤.៣. អនាម័យនៅតាមសាលារៀន គ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀតនៅតាមជនបទ**

- បង្កើតនូវបទដ្ឋានថ្នាក់ជាតិដែលមានការកំណត់ពីចំនួនសិស្សនិងបុគ្គលិកសម្រាប់បង្គន់នីមួយៗ និងមានការបែងចែកបន្ទប់បង្គន់សម្រាប់ក្មេងប្រុស ក្មេងស្រី បុគ្គលិក និងកុមារពិការ
- រៀបចំនិងថែទាំបញ្ជីសារពើភណ្ឌសំណង់ផ្គត់ផ្គង់ទឹកនិងសំណង់បង្គន់អនាម័យដែលមានស្រាប់ក្នុងសាលារៀន រួមបញ្ចូលទាំងស្ថានភាពធ្វើឱ្យដំណើរការបង្គន់អនាម័យនិងទឹកនៅគ្រប់សាលារៀនទាំងអស់
- សាងសង់បង្គន់អនាម័យសមស្របនៅតាមសាលារៀនទាំងអស់ក្នុងតំបន់ជនបទ ដើម្បីឆ្លើយតបទៅតាមតម្រូវការ
- បង្កើតនិងផ្តល់នូវការអប់រំមូលដ្ឋានពីបំណិនជីវិតដែលជាផ្នែកមួយនៃកម្មវិធីសិក្សាស្នូល ស្របគ្នាជាមួយនឹងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ
- បង្កើតបទដ្ឋានថ្នាក់ជាតិដែលមានកំណត់ពីចំនួនអ្នកជំងឺសម្រាកក្នុងមណ្ឌលសុខភាព និងអ្នកជំងឺដែលមកពិគ្រោះជំងឺសម្រាប់បង្គន់អនាម័យនីមួយៗ ដោយមានការបែងចែកបន្ទប់បង្គន់ សម្រាប់បុរស ស្ត្រី និងជនពិការ
- រៀបចំនិងថែរក្សាបញ្ជីសារពើភណ្ឌនៃសំណង់ផ្គត់ផ្គង់ទឹកនិងបង្គន់អនាម័យដែលមានស្រាប់ ដោយរាប់បញ្ចូលទាំងស្ថានភាពដំណើរការរបស់វា នៅតាមគ្រឹះស្ថានសុខាភិបាលនិងស្ថាប័នដទៃទៀតនៅជនបទ
- សាងសង់បង្គន់អនាម័យនៅគ្រប់គ្រឹះស្ថានសុខាភិបាលនិងស្ថាប័នដទៃទៀតនៅជនបទ ដើម្បីឆ្លើយតបតាមតម្រូវការ
- ធ្វើការសិក្សានិងត្រួតពិនិត្យប្រព័ន្ធបង្ហូរកាកសំណល់រាវ ដើម្បីវាយតម្លៃទំហំនៃបញ្ហានិងសំណើដំណោះស្រាយជាយុទ្ធសាស្ត្រ
- ធ្វើការសិក្សានិងត្រួតពិនិត្យកាកសំណល់រឹង ដើម្បីវាយតម្លៃទំហំនៃបញ្ហា និងសំណើដំណោះស្រាយជាយុទ្ធសាស្ត្រ
- អភិវឌ្ឍនិងអនុវត្តផែនការដើម្បីដោះស្រាយការបង្ហូរកាកសំណល់រាវ និងការទុកដាក់សំណល់រឹង។

**៦.៥. ជំរុញនិងលើកទឹកចិត្តប្រជាជនឱ្យមានការផ្លាស់ប្តូរឥរិយាបថ ក្នុងការប្រើប្រាស់ទឹកស្អាតនិងអនាម័យប្រកបដោយនិរន្តភាព**

សកម្មភាពសម្រាប់អនុវត្តក្នុងរយៈពេលខ្លី មធ្យម និងវែង មានដូចខាងក្រោម៖

- ផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន តាមដានត្រួតពិនិត្យការអនុវត្តនិងវាយតម្លៃប្រសិទ្ធភាពនៃការផ្លាស់ប្តូរទម្លាប់ក្នុងការប្រតិបត្តិអនាម័យល្អ
- ពិនិត្យមើលឡើងវិញនិងកែសម្រួលគោលការណ៍ណែនាំស្តីពីការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន បន្ទាប់ពីការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍ណែនាំនេះ
- ធ្វើការអង្កេតទិន្នន័យមូលដ្ឋាន និងតាមដានការអនុវត្តអនាម័យ ហើយរាយការណ៍លទ្ធផលទៅឱ្យការិយាល័យអភិវឌ្ឍន៍ជនបទស្រុក
- ធ្វើយុទ្ធនាការផ្សព្វផ្សាយពីការផ្លាស់ប្តូរឥរិយាបថអនាម័យផ្ទាល់ខ្លួន នៅតាមសហគមន៍និងតាមផ្ទះ
- ធ្វើការអប់រំបណ្តុះបណ្តាលជាទៀងទាត់និងវគ្គបំប៉នស្តីពីការផ្លាស់ប្តូរឥរិយាបថអនាម័យផ្ទាល់ខ្លួន។

## ៧. ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ បានមកពីថវិកាជាតិ ផ្នែកឯកជន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងសប្បុរសជន។

## ៨. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីអនុវត្តផែនការសកម្មភាពនិងការត្រួតពិនិត្យវាយតម្លៃផែនការយុទ្ធសាស្ត្រជាតិនេះ ត្រូវអនុវត្តជាពីរដំណាក់កាលគឺ

(១) ដំណាក់កាលទី១ ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ និង

(២) ដំណាក់កាលទី២ ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៥។

នៅក្នុងដំណើរការអនុវត្ត នឹងមានការត្រួតពិនិត្យនិងតាមដានពាក់កណ្តាលអាណត្តិ នៅក្នុងឆ្នាំ២០១៨ និងការវាយតម្លៃចុងក្រោយនៅកំឡុងឆ្នាំ២០២៥។

ផែនការយុទ្ធសាស្ត្រជាតិនេះ គ្របដណ្តប់រយៈពេលពីឆ្នាំ២០១៤ដល់២០២៥ ដែលជាកាលបរិច្ឆេទកំណត់ក្នុងគោលនយោបាយជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ដើម្បីសម្រេចឱ្យបានទស្សនវិស័យរបស់វិស័យនេះ ក្នុងការផ្តល់លទ្ធភាពទទួលបានសេវាដល់ប្រជាជននៅតាមជនបទទាំងអស់។ ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ ជារយៈពេលដែលនឹងត្រូវមានការផ្លាស់ប្តូរធំៗ ក្នុងការរៀបចំស្ថាប័ននិងការកសាងសមត្ថភាព។ គោលបំណងគឺធ្វើឱ្យមានការផ្លាស់ប្តូរឱ្យបានទាន់ពេលវេលា ដើម្បីឆ្លើយតបទៅនឹងកំណើនដ៏ធំធេងនៃការផ្តល់សេវាដែលត្រូវការ ចន្លោះឆ្នាំ២០១៤និង២០២៥។

| សកម្មភាព | កាលបរិច្ឆេទ |
|---|---|
| បង្កើតគោលការណ៍ណែនាំនិងផែនការសកម្មភាពដើម្បីអនុវត្ត | ឆ្នាំ២០១៤ |
| ការអនុវត្តផែនការសកម្មភាពលើកទី១ | ឆ្នាំ២០១៤-២០១៨ |
| ធ្វើការត្រួតពិនិត្យនិងវាយតម្លៃលើកទី១ | ឆ្នាំ២០១៨ |
| ការអនុវត្តផែនការសកម្មភាពលើកទី២ | ឆ្នាំ២០១៩-២០២៥ |
| ធ្វើការត្រួតពិនិត្យនិងវាយតម្លៃចុងក្រោយ | ឆ្នាំ២០២៥ |

ក្រសួងអភិវឌ្ឍន៍ជនបទត្រូវពិនិត្យឡើងវិញតាមកាលកំណត់ទៀងទាត់ លើការវិវត្តនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ។ ប្រសិនបើមានការចាំបាច់ ក្រសួងត្រូវធ្វើការកែតម្រូវ ដោយយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរនៃតម្រូវការនិងកាលៈទេសៈ ជាពិសេស ទៅលើការឆ្លើយតបទៅនឹងដំណើរការវិវត្តសេដ្ឋកិច្ចសង្គមកម្ពុជា។

## ៩. សេចក្តីសន្និដ្ឋាន

ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំផែនការយុទ្ធសាស្ត្រជាតិនេះឡើង ក្នុងគោលដៅបង្កើនការផ្គត់ផ្គង់ទឹកស្អាត លើកកម្ពស់អនាម័យនៅជនបទ បង្កើតបរិយាកាសសមស្រប និងប្រមូលធនធានឱ្យបានគ្រប់គ្រាន់។ យុទ្ធសាស្ត្រជាតិនេះបានកំណត់វិធានការនានា ដែលរួមមានការរៀបចំពង្រឹងស្ថាប័ន ការស្រាវជ្រាវបណ្តុះ

បណ្តាល ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ ការពង្រឹងគុណភាពសេវាកម្ម ការវិនិយោគទុន និងការចូលរួមរបស់ផ្នែកឯកជនជាដើម។ ការអនុវត្តប្រកបដោយជោគជ័យនៃផែនការយុទ្ធសាស្ត្រជាតិនេះ នឹងបង្កើតឱ្យមានផលចំណេញផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងការចូលរួមចំណែកសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដូចជា ការលើកកម្ពស់សុខុមាលភាពប្រជាជន ការកាត់បន្ថយជំងឺរាក ការកាត់បន្ថយអត្រាកង្វះអាហារូបត្ថម្ភ ការកាត់បន្ថយមរណភាពកុមារនិងមាតា ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ ការផ្លាស់ប្តូរទម្លាប់អនាម័យ សំដៅលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជននៅជនបទ និងការកាត់បន្ថយភាពក្រីក្រ ប្រកបដោយសមធម៌និងមាននិរន្តរភាព។ ដើម្បីឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះទទួលបានជោគជ័យ ទាមទារឱ្យមានការគាំទ្រនិងការចូលរួមពីគ្រប់ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល ផ្នែកឯកជន និងសហគមន៍។

# សទ្ទានុក្រម

**ការទទួលបានការផ្គត់ផ្គង់ទឹកស្អាត(Access to water supply services)** សំដៅដល់លទ្ធភាពទទួលបានប្រភពទឹកកែលម្អមួយ ដែលស្ថិតនៅក្នុងបរិវេណ១៥០ម៉ែត្រពីលំនៅឋានអ្នកប្រើប្រាស់។ ប្រភពទឹកកែលម្អគឺជាប្រភពទឹកដែលអាចផ្តល់ទឹកសុវត្ថិភាព ដូចជាការតបណ្តាញទឹកនៅតាមផ្ទះនិងទឹកបានមកពីអណ្តូងខួងជាដើម។

**ការទទួលបានអនាម័យសមស្រប (Access to adequate sanitation)** សំដៅដល់លទ្ធភាពទទួលបានអនាម័យកែលម្អត្រឹមត្រូវមួយនៅតាមលំនៅឋាន។

**ការផ្គត់ផ្គង់ទឹក(Water supply)** សំដៅដល់ទឹកប្រើប្រាស់ក្នុងផ្ទះ ដូចជាទឹកសម្រាប់ផឹក លាងសម្អាត ងូត និងទឹកប្រើប្រាស់សម្រាប់សកម្មភាពសេដ្ឋកិច្ចតាមផ្ទះមួយចំនួនទៀត។

**ការផ្គត់ផ្គង់ទឹកដែលមានការកែលម្អ(Improved water supply)** សំដៅដល់ទឹកបានពីប្រភពដែលទំនងជាផ្តល់នូវទឹកសុវត្ថិភាព ដូចជាទឹកតបណ្តាញតាមផ្ទះនិងទឹកដែលបានមកពីការខួងអណ្តូងជាដើម។

**ការវាយតម្លៃ(Evaluation)** សំដៅដល់ការត្រួតពិនិត្យ ការប្រមូល និងការវិភាគព័ត៌មានអំពីការអតិវឌ្ឍគម្រោងកន្លងមក ដើម្បីធ្វើការសម្រេចចិត្តលើការបន្តគម្រោងនិង/ឬកែលម្អការអនុវត្តគម្រោងដែលមានភាពស្រដៀងគ្នានិងវិស័យ ទាំងមូលតែម្តង។

**ក្រុមប្រើប្រាស់ទឹកនិងអនាម័យ(Water and Sanitation User Group)** សំដៅដល់ក្រុមមនុស្សចំនួន០៥នាក់ដែលបានបង្កើតឡើងដោយសហគមន៍ដើម្បីទទួលខុសត្រូវលើប្រភពទឹកស្អាតមាន ដូចជាអណ្តូងគ្រប់ប្រភេទ ប្រព័ន្ធចែកចាយទឹកខ្នាតតូច និងស្រះទឹកសហគមន៍។ ក្រុមនេះមានតួនាទីថែទាំនិងជួសជុលពេលអណ្តូងខូច និងជាតំណាងឲ្យអ្នកប្រើប្រាស់ទឹកដទៃទៀតនៅតាមចំណុចអណ្តូងនីមួយៗ។

**ជនបទ** សំដៅដល់ទីតាំងភូមិសាស្ត្ររដ្ឋបាលដែលមានដង់ស៊ីតេប្រជាជនយ៉ាងច្រើនបំផុត២០០នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា ឬភាគរយនៃបុរសធ្វើការក្នុងវិស័យកសិកម្មចាប់ពី៥០ភាគរយ ឬចំនួនប្រជាជនសរុបនៅក្នុងឃុំយ៉ាងច្រើនបំផុត២ ០០០នាក់។

**ទីប្រជុំជន** សំដៅដល់ឃុំដែលកំណត់ថាជាទីប្រជុំជនបានលុះត្រាតែឃុំនោះមានលក្ខខណ្ឌបីដូចខាងក្រោម៖

១- ដង់ស៊ីតេប្រជាជនលើសពី២០០នាក់ក្នុងមួយគីឡូម៉ែត្រក្រឡា។

២- ភាគរយនៃបុរសធ្វើការក្នុងវិស័យកសិកម្មក្រោម៥០ភាគរយ។

៣- ចំនួនប្រជាជនសរុបនៅក្នុងឃុំលើសពី២០០០នាក់។

**បដិភាគ(Contribution)** សំដៅដល់ថវិការបស់រដ្ឋាភិបាល និងសហគមន៍អ្នកទទួលផលត្រូវចូលរួមនៃការចំណាយទុនដើមសម្រាប់ការសាងសង់សំណង់ទឹកស្អាតនិងអនាម័យ និងថវិកាចំណាយលើការចំណាយចរន្តសម្រាប់ការប្រើប្រាស់និងថែទាំសមិទ្ធផលទឹកស្អាតនិងអនាម័យ។

**បរិស្ថានប្រកបដោយអនាម័យ(Hygienic environment)** សំដៅដល់បរិស្ថានដែលស្អាត ហើយមិនអាចបង្កឱ្យមានជំងឺពាក់ព័ន្ធនឹងទឹកនិងលាមក។

**ប្រភពទឹក(Water source)** សំដៅដល់កន្លែងដែលទឹកអាចត្រូវបានទាញយកមកប្រើ ដូចជាកន្លែងទឹកចេញតាមភ្នំឬអណ្តូង។ ប្រភពទឹកនេះអាចជាទន្លេឬក៏បឹងផងដែរ អាស្រ័យលើបរិបទ។

**ទឹកស្អាត(Clean water)** សំដៅដល់ទឹកបរិភោគបានមកពីប្រភពទឹកមានការកែលម្អទាំងឡាយដូចជា អណ្តូងស្នប់ជ្រៅ អណ្តូងស្នប់រាក់ អណ្តូងលូដែលមានការការពារ និងទឹកភ្លៀងដែលមានការការពារ ហើយគឺជាទឹកដែលមានគុណភាពស្របតាមគោលការណ៍ណែនាំជាតិស្តីពីគុណភាពទឹកជនបទ។

**ទឹកសម្រាប់បរិភោគ(Drinking Water)** សំដៅដល់ទឹកដែលមានគុណភាពស្របតាមបទដ្ឋានស្តង់ដាគុណភាពទឹកស្អាត ហើយមានសុវត្ថិភាពក្នុងការទទួលទាន។

**សហគមន៍ជនបទ(Rural communities)** សំដៅដល់ការតាំងភូមិលំនៅ ដែលមានទីតាំងស្ថិតនៅភូមិសាស្ត្រក្រៅតំបន់ទីក្រុង។

**សេវាប្រកបដោយនិរន្តរភាព(Sustainable services)** សំដៅដល់សេវាផ្សេងៗដែលមានទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស សម្រាប់ប្រតិបត្តិការ ការថែទាំ និងការផ្លាស់ប្តូរគ្រឿងបន្លាស់ និងការយកចិត្តទុកដាក់ទៅលើទិដ្ឋភាពបច្ចេកទេស សង្គម ស្ថាប័ន និងបរិស្ថាន ដើម្បីឱ្យសេវាទាំងនេះអាចបន្តផ្តល់នូវសេវាជាមូលដ្ឋានដែលអាចទទួលយកបាន។

**ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតនិងអនាម័យ(Infrastructure of Rural Water Supply and Sanitation)** សំដៅដល់សំណង់ទឹកស្អាត និងបង្គន់អនាម័យគ្រប់ប្រភេទដែលបានផ្គត់ផ្គង់ជូននៅតាមមូលដ្ឋានមានអណ្តូងស្នប់ជ្រៅ អណ្តូងស្នប់រាក់ អណ្តូងលូ អណ្តូងចម្រុះ ស្រះសហគមន៍ ប្រព័ន្ធចែកចាយទឹកខ្នាតតូច និងបង្គន់អនាម័យតាមគ្រួសារ។

**អនាម័យផ្ទាល់ខ្លួន(Hygiene)** សំដៅដល់ឥរិយាបថទាំងឡាយដែលទាក់ទងទៅនឹងការទុកនិងការប្រើប្រាស់ទឹកនៅក្នុងផ្ទះ ព្រមទាំងការអនុវត្តអនាម័យផ្សេងៗ។ អនាម័យផ្ទាល់ខ្លួនល្អ គឺជាការអនុវត្តមួយដែលធ្វើឱ្យខ្លួនយើង ការរស់នៅរបស់យើង និងទីកន្លែងដែលយើងធ្វើការស្អាតជានិច្ច ដើម្បីការពារមិនឱ្យឆ្លងជំងឺផ្សេងៗ។

**អនាម័យដែលមានការកែលម្អ(Improved sanitation)** សំដៅដល់បង្គន់ចាក់ទឹកដែលត្រូវបានភ្ជាប់ទៅនឹងប្រព័ន្ធលូបង្ហូរទឹកស្អុយ ឬភ្ជាប់ទៅនឹងអាងស្តុកលាមក ឬរណ្តៅមានគម្រប បង្គន់ស្ងួតដែលមានផែន ឬបង្គន់អនាម័យ ដែលមានទុយោខ្យល់ចេញចូលក្នុងរណ្តៅ។

**អនាម័យ(Sanitation)** សំដៅដល់ការគ្រប់គ្រងនិងការទុកដាក់កាកសំណល់រាវ(ទឹកនោម) និងលាមករបស់មនុស្ស និងកាកសំណល់រាវដែលបានមកពីការប្រើប្រាស់តាមផ្ទះ។

**អាសេនិក(Arsenic)** សំដៅដល់សារធាតុគីមីម្យ៉ាងដែលកកើតឡើងពីធម្មជាតិ និងក៏អាចកើតឡើងពីសកម្មភាពរបស់មនុស្សដែរបានចម្លងចូលទៅក្នុងប្រភពទឹកក្នុងដីនិងលើផ្ទៃដី។ សារធាតុអាសេនិក គ្មានរសជាតិ គ្មានក្លិន គ្មានពណ៌ ហើយវាអាចចម្លងចូលខ្លួនមនុស្សបានគឺតាមរយៈការបរិភោគទឹក និងតាមរយៈការយកទឹកសម្រាប់ចម្អិនអាហារតែប៉ុណ្ណោះ។ បើយើងបរិភោគទឹកដែលមានសារធាតុអាសេនិកនេះលើសស្តង់ដាទឹកជាតិ វានឹងធ្វើឱ្យប៉ះពាល់ដល់សុខភាព។ គុណភាពទឹកជនបទពាក់ព័ន្ធសារធាតុអាសេនិកដែលអាចបរិភោគបាន និងមិនប៉ះពាល់សុខភាព សំដៅដល់ទឹកដែលមានផ្ទុកសារធាតុអាសេនិកមិនលើសពី៥០មីក្រូក្រាមក្នុង ១លីត្រទឹក(៥០ppb)។

ត្រូវមានការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព" ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះក្រុមការងារទាំងអស់ រួមមានក្រសួងអភិវឌ្ឍន៍ជនបទ អន្តរក្រសួង ជាពិសេសទីស្តីការគណៈរដ្ឋមន្ត្រី និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានខិតខំប្រឹងប្រែងរៀបចំផែនការយុទ្ធសាស្ត្រជាតិនេះឡើង ។

ខ្ញុំសូមអំពាវនាវដល់សហគមន៍ទាំងមូលត្រូវចូលរួមគាំទ្រឱ្យបានខ្លាំងក្លា ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះទទួលបានជោគជ័យ ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងជួររាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នឹងយកផែនការយុទ្ធសាស្ត្រជាតិនេះទៅប្រើប្រាស់ជាត្រីវិស័យសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធភាព ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**